# ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


១១-៨-២០០៩ -ព្រះរាជក្រម នស/រកម/០៨០៩/០១២ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីអនុម័តយល់ព្រម លើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតុប្រជាធិបតេយ្យកូរ៉េ ស្តីពីការជំរុញ និង ការការពារវិនិយោគ ៥៨៦១


### ២-ព្រះរាជក្រឹត្យ


១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨០៧ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សា ឯកឧត្តម ខួន ញ៉ិល អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥៨៨២

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨០៨ ស្តីពីការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម ចំនួន ០២ រូប ៥៨៨៣

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨០៩ ស្តីពីការតម្លើង ឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហាន ក្រសួងការពារជាតិ និង មេបញ្ជាការរងកងពលតូចលេខ ៣១ ចំនួន ០២ រូប ៥៨៨៥

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១០ ស្តីពី :

*១*-ការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម ចំនួន ៣២ រូប និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចំនួន ០១ រូប

*២*-ការតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចំនួន ៤២ រូប ៥៨៨៦

១០-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨១២ ស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការស៊ីវិលនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួង សាធារណការ និង ដឹកជញ្ជូន ចំនួន ០១ រូប, តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ចំនួន ០៤ រូប និង តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងព័ត៌មាន តាមកម្រិតសញ្ញាប័ត្រ ចំនួន ០១ រូប ៥៨៩១

## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

១២-៨-២០០៩ -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្ដីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ៥៨៩៤

២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៤៥ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៥៩១៥

២៧-៧-២០០៩ -អនុក្រឹត្យលេខ ១២៤៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥៩៦៥

### ២_សេចក្ដីសំរេច

០៥-៨-២០០៩ -សេចក្ដីសំរេចលេខ ៤៩ សសរ ស្ដីពីការដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិ ស្ដីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម សម្រាប់រយៈពេល ០៣ ឆ្នាំ (២០០៩-២០១១) ៥៩៦៦

០៥-៨-២០០៩ -សេចក្ដីសំរេចលេខ ៥០ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលលើវិស័យពិការភាព ៥៩៦៧

១១-៨-២០០៩ -សេចក្ដីសំរេចលេខ ៥១ សសរ ស្ដីពីការបង្កើតក្រុមការងារដឹកនាំ ដំណើរការសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និង ហិរញ្ញប្បទានសហប្រតិបត្តិការ ៥៩៧១

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ព្រមគ្រប់តាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ ស្តីពីការជំរុញ និងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចរល.០៩០៨.៧៣៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៣៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ
# ស្តីពី
# ការជំរុញ និងការការពារវិនិយោគ

៚៚៚✿៚៚៚

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (ចាប់ពីពេលនេះតទៅហៅថា "ភាគីជាប់កិច្ចសន្យា")

ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងរដ្ឋទាំងពីរ លើមូលដ្ឋានស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក

ក្នុងស្មារតីបង្កើត និងធានានូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការវិនិយោគ ដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងនៅក្នុងដែនដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

ដោយទទួលស្គាល់ថា ការជំរុញ និងការការពារនូវការវិនិយោគដូចនេះ នឹងនាំទៅរកការកើនឡើងនូវគំនិតផ្តួចផ្តើមធុរកិច្ចនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាទាំងពីរ និងវិបុលភាពសេដ្ឋកិច្ចរបស់រដ្ឋទាំងពីរ

បានព្រមព្រៀងគ្នាដូចតទៅៈ

## មាត្រា ១
## និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១) **"ការវិនិយោគ "** សំដៅដល់ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានធ្វើការវិនិយោគ ដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាមួយនៅក្នុងដែនដីនៃភាគីជាប់កិច្ចសន្យាមួយទៀត ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីម្ចាស់ផ្ទះ និងជាពិសេសមានជាអាទិ៍:

ក) ចលនៈទ្រព្យ និងអចលនៈទ្រព្យ ព្រមទាំងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀតដូចជាការបញ្ចាំ និងការសន្យាធានា

ខ) ភាគហ៊ុន ស្តុក ប័ណ្ណបំណុល ព្រមទាំងទ្រង់ទ្រាយដទៃទៀតនៃភាគកម្មនៅក្នុងក្រុមហ៊ុន

គ) ការទាមទារពាក់ព័ន្ធទៅនឹងរូបិយវត្ថុ ឬការបំពេញកាតព្វកិច្ចដទៃទៀត ដែលមានតំលៃសេដ្ឋកិច្ច

ឃ) សិទ្ធិចម្លង សិទ្ធិលើទ្រព្យសម្បត្តិឧស្សាហកម្ម ដូចជា សិទ្ធិលើប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា សេវាសញ្ញា ពាណិជ្ជនាម គំនូរឧស្សាហកម្ម ការបង្ហាញពីប្រភពដើម កេរ្តិ៍ឈ្មោះជំនួញ និងសិទ្ធិប្រហាក់ប្រហែលដទៃទៀត

ង) សម្បទានខាងធុរកិច្ចដែលទទួលស្គាល់ដោយច្បាប់ ឬ តាមកិច្ចសន្យា ឬ តាមសេចក្តីសម្រេចនៃអាជ្ញាធរ ដោយអនុលោមទៅតាមច្បាប់ រួមបញ្ចូលសម្បទានសម្រាប់ការស្រាវជ្រាវការជាំផុះ ការធ្វើនិស្សារណកម្ម ឬការធ្វើអាជីវកម្មធនធានធម្មជាតិ ។

ការប្តូរទ្រង់ទ្រាយនៃទ្រព្យសម្បត្តិដែលបានវិនិយោគ ឬបានធ្វើការវិនិយោគជាថ្មីឡើងវិញ មិនមានឥទ្ធិពលទៅលើចរិតលក្ខណៈនៃការវិនិយោគទេ ប្រសិនបើការវិនិយោគ ឬការវិនិយោគជាថ្មីឡើងវិញនោះ មិនផ្ទុយទៅនឹងច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ដែលការវិនិយោគបានធ្វើនៅក្នុងដែនដីនោះ ។

២) **"អ្នកវិនិយោគ "** សម្រាប់ភាគីជាប់កិច្ចសន្យាណាមួយសំដៅដល់:

ក) រូបវ័ន្តបុគ្គល ដែលអនុលោមទៅតាមច្បាប់នៃភាគីជាប់កិច្ចសន្យានោះត្រូវបានសន្មតថា ជាជនជាតិរបស់ខ្លួន

ខ) នីតិបុគ្គល ដែលរួមមាន ក្រុមហ៊ុន សមាគមធុរកិច្ច និងអង្គការដទៃទៀត ដែលបានបង្កើតឡើង ឬបើមិនដូចនេះទេ បានរៀបចំឡើងដោយត្រឹមត្រូវស្របតាមច្បាប់ នៃភាគីជាប់កិច្ចសន្យានោះ ហើយដែលមានទីស្នាក់ការ និង មានសកម្មភាពសេដ្ឋកិច្ចរួមគ្នានៅក្នុងដែនដីរបស់ភាគីជាប់កិច្ចសន្យាដដែល ។

៣) **"និន្នផល "** សំដៅដល់ប្រាក់ដែលបានមកពីការវិនិយោគ ដែលមានជាអាទិ៍ ប្រាក់ចំណេញ ការប្រាក់ភាគលាភ ចំណេញមូលធន សួយសារ និង កំរៃ ។

៤) "ដែនដី " សំដៅដល់

(១) ចំពោះព្រះរាជាណាចក្រកម្ពុជា គឺ រាល់ដែនដីគោក ដែនសមុទ្រ បាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រព្រមទាំងដែនអាកាស ដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអំណាចប្រតិបត្តិនូវសិទ្ធិ ឬយុត្តាធិការ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន និងច្បាប់អន្តរជាតិ ។

(២) ចំពោះសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ គឺដែនដីគោក ដែនសមុទ្រ តំបន់សេដ្ឋកិច្ចពិសេសជាប់សមុទ្រ និង លូងសមុទ្រ ដែលខ្លួនមានសិទ្ធិអំណាចប្រតិបត្តិនូវសិទ្ធិ ឬ យុត្តាធិការ ដោយ អនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន និង ច្បាប់អន្តរជាតិ ។

## មាត្រា ២
## ការជំរុញ និង ការការពារវិនិយោគ

១) ភាគីជាប់កិច្ចសន្យានីមួយៗត្រូវជម្រុញការវិនិយោគ ដែលធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងទឹកដីរបស់ខ្លួន ដោយបង្កនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការវិនិយោគរបស់ពួកគេ និងផ្តល់នូវការយល់ព្រមដល់ការវិនិយោគនោះ ដោយអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ។ នៅពេលដែលភាគីជាប់កិច្ចសន្យាមួយបានយល់ព្រមអោយធ្វើវិនិយោគនៅក្នុងទឹកដីរបស់ខ្លួនគេក៏ត្រូវផ្តល់ផងដែរនូវការសម្រួល សម្រាប់ការចូលមកស្នាក់នៅរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ឬបុគ្គលិករបស់ពួកគេ ដែលមានបំណងចូលមកក្នុងទឹកដីរបស់ខ្លួន ទាក់ទងទៅនឹងការធ្វើវិនិយោគនេះ ។

២) ការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតត្រូវបានផ្តល់ឱ្យគ្រប់ពេលវេលានូវប្រព្រឹត្តិកម្មត្រឹមត្រូវនឹងយុត្តិធម៌ និងទទួលបាននូវការការពារ និងសន្តិសុខពេញលេញ ។ ពុំមានភាគីជាប់កិច្ចសន្យាណាមួយ នឹងធ្វើឱ្យខូចប្រយោជន៍ដល់ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផល ឬការចាត់ចែងនៃការវិនិយោគ ដោយវិធានការមិនសមហេតុផល ឬរើសអើងឡើយ ។

## មាត្រា ៣
## ប្រព្រឹត្តកម្ម នៃការវិនិយោគ

១) ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវអនុញ្ញាតចំពោះការវិនិយោគ និងទិន្នផលនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងទឹកដីរបស់ខ្លួននូវប្រព្រឹត្តិកម្ម ដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមចំពោះការវិនិយោគ និងទិន្នផលនៃអ្នកវិនិយោគរបស់ជនជាតិខ្លួន ឬអ្នកវិនិយោគនៃរដ្ឋទីបីណាមួយ ពោលគឺផ្តល់នូវភាពអនុគ្រោះណាដែលមានលក្ខណៈប្រសើរជាង ។

២) ភាគីជាប់កិច្ចសន្យានីមួយៗត្រូវអនុញ្ញាតឱ្យអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួនទាក់ទងទៅនឹងការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផល ឬការចាត់ចែង នៃការវិនិយោគរបស់គេនូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលខ្លួន បានអនុញ្ញាតឱ្យអ្នកវិនិយោគរបស់ជនជាតិខ្លួន ឬអ្នកវិនិយោគនៃរដ្ឋទីបីណាមួយពោលគឺផ្តល់នូវភាពអនុគ្រោះណា ដែលមានលក្ខណៈប្រសើរជាង ។

៣) បញ្ញត្តិនៃប្រព្រឹត្តិកម្មសម្រាប់ប្រជាជាតិទទួលបាននូវការអនុគ្រោះបំផុតនៃមាត្រានេះ មិនត្រូវយកមកបកស្រាយ ដើម្បីតម្រូវឱ្យភាគីជាប់កិច្ចសន្យាម្ខាងផ្តល់ដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវផលប្រយោជន៍នៃប្រព្រឹត្តិកម្មណាមួយ ភាពអនុគ្រោះ ឬ បុព្វសិទ្ធិដែលបានផ្តល់ដោយភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ ដោយផ្អែកទៅលើ:

ក) សហព័ន្ធគយ តំបន់សេដ្ឋកិច្ចសេរី កិច្ចព្រមព្រៀងសហព័ន្ធហិរញ្ញវត្ថុ ឬកិច្ចព្រមព្រៀងអន្តរជាតិប្រហាក់ប្រហែល ដែលឈានទៅរកសហព័ន្ធនោះឬទំរង់ដទៃទៀត នៃសហប្រតិបត្តិការក្នុងតំបន់ ដែលភាគីជាប់កិច្ចសន្យាណាមួយ ជាគូភាគី ឬអាចនឹងក្លាយទៅជាគូភាគី

ខ) កិច្ចព្រមព្រៀងអន្តរជាតិ ឬ ការសំរបសំរួលណាមួយដែលទាក់ទងទាំងស្រុង ឬជាចំបងដល់កិច្ចការសារពើពន្ធ

## មាត្រា ៤
## អស្សាមិករណ៍

១) ការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាណាមួយ មិនត្រូវបានដកហូតធ្វើជាតូបនីយកម្ម ឬទទួលរងនូវវិធានការដែលមានឥទ្ធិពលដូចគ្នា (តទៅនេះហៅថា អស្សាមិករណ៍) នៅក្នុងទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ លើកលែងតែទង្វើនោះធ្វើឡើងដើម្បីបំរើផលប្រយោជន៍សាធារណៈ តាមនីតិវិធីនៃច្បាប់ ដោយឈរលើមូលដ្ឋានគ្មានការរើសអើង និងបានផ្តល់នូវសំណងភ្លាមៗ ពេញលេញ និងមានប្រសិទ្ធិភាព ។

២) សំណងត្រូវគណនាទៅនឹងតម្លៃទីផ្សារនៃការវិនិយោគ ដែលបានដកហូតនៅពេលភ្លាមៗ មុនពេលធ្វើអស្សាមិករណ៍ ឬនៅមុនពេលដែលអស្សាមិករណ៍នោះត្រូវបានដឹងជាសាធារណៈ អាស្រ័យទៅតាមករណីណាមួយដែលកើតមុន ។ សំណងនោះត្រូវបូកបញ្ចូលផងដែរនូវការប្រាក់ដែលបានកើតមានតាមអត្រាពាណិជ្ជកម្មសមស្រប គិតពីថ្ងៃដែលត្រូវធ្វើការសង រហូតដល់ថ្ងៃទូទាត់ជាក់ស្តែង នឹងត្រូវបានទូទាត់ដោយរូបិយវត្ថុដែលអាចប្តូរបានដោយសេរី ពុំមានការពន្យារពេលទៅឱ្យជនដែលមានសិទ្ធិត្រូវទទួល ។

## មាត្រា ៥
## សំណងចំពោះការខាតបង់

អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាមួយ ដែលការវិនិយោគរបស់គេទទួលរងនូវការខាតបង់ដោយសារសង្គ្រាម ឬជម្លោះប្រដាប់អាវុធដទៃទៀត បដិវត្តន៍ ស្ថានភាពប្រទេសជាតិស្ថិតក្នុងភាពមានអាសន្ន ការបះបោរ ភាពចលាចល កុប្បកម្ម ឬ ព្រឹត្តិការណ៍ប្រហាក់ប្រហែលគ្នាដទៃទៀតនៅក្នុងទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ត្រូវតែបានយល់ព្រមពីភាគីជាប់កិច្ចសន្យានេះនូវប្រព្រឹត្តិកម្មស្របទៅតាម មាត្រា ៣ នៃកិច្ចព្រមព្រៀងនេះ ទាក់ទងទៅនឹងសំណង សំណងជួសជុល សំណងប៉ះប៉ូវ ឬ ដំណោះស្រាយដទៃទៀត។

## មាត្រា ៦
## ការផ្ទេរដោយសេរី

១) ភាគីជាប់កិច្ចសន្យានីមួយៗដែលការវិនិយោគបានធ្វើនៅក្នុងទឹកដីរបស់ខ្លួនដោយអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ត្រូវផ្តល់ទៅឱ្យអ្នកវិនិយោគទាំងនោះនូវការផ្ទេរដោយសេរី ជារូបិយវត្ថុ ដែលអាចប្តូរបានដោយសេរីនូវមូលនិធិទាក់ទងទៅនឹងការវិនិយោគទាំងនោះជាពិសេស :

ក) មូលធន ឬ ចំនួនមូលធនបន្ថែមដែលជាតម្រូវការចាំបាច់សម្រាប់ទ្រទ្រង់ និង អភិវឌ្ឍន៍ការវិនិយោគ

ខ) ទិន្នផល

គ) ការទូទាត់សងនូវប្រាក់កម្ចីទាក់ទងទៅនឹងការវិនិយោគ

ឃ) ទ្រព្យសម្បត្តិមួយផ្នែក ឬទាំងអស់ដែលបានមកពីការលក់ ឬការរំលាយការវិនិយោគ

ង) សំណង ឬការទូទាត់ដទៃទៀតដែលត្រូវសង ស្របតាមមាត្រា ៤ និង ៥

ច) ប្រាក់បៀវត្ស និងចំណូលស្របច្បាប់ដទៃទៀត នៃបុគ្គលដែលបំពេញការងារនៅក្រៅប្រទេស ទាក់ទងទៅនឹងការវិនិយោគ

ឆ) ការទូទាត់សងដែលកើតចេញពីការដោះស្រាយវិវាទ

២) ការផ្ទេរត្រូវធ្វើឡើងដោយមិនមានការពន្យារពេលទៅតាមអត្រាប្តូរប្រាក់ទីផ្សារ នាថ្ងៃផ្ទេរនៅក្នុងទឹកដី នៃភាគីជាប់កិច្ចសន្យានោះ ។

៣) ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវអនុញ្ញាតឱ្យអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្ម ដែលមានភាពអនុគ្រោះ មិនតិចជាងអ្វីដែលបានអនុញ្ញាតឱ្យអ្នកវិនិយោគនៃរដ្ឋទីបីណាមួយ ទាក់ទងទៅនឹងការផ្ទេរ ។

## មាត្រា ៧
## ឧបាទេសកម្ម

១) ប្រសិនបើភាគីជាប់កិច្ចសន្យាណាមួយ ឬភ្នាក់ងារ ដែលខ្លួនបានតែងតាំងធ្វើការទូទាត់ទៅឱ្យអ្នកវិនិយោគណាម្នាក់របស់គេ នូវការធានាផ្អែកហិរញ្ញវត្ថុទប់ទល់នឹងហានិភ័យមិនមែនពាណិជ្ជកម្ម ដែលខ្លួនបានអនុញ្ញាតចំពោះការវិនិយោគដែលធ្វើដោយអ្នកវិនិយោគរបស់គេ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ ភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះត្រូវទទួលស្គាល់ :

ក) ការផ្ទេរសិទ្ធិដោយអនុលោមទៅតាមច្បាប់ ឬ ផ្អែកទៅលើប្រតិបត្តិការស្របច្បាប់នូវសិទ្ធិ ឬការតវ៉ាណាមួយពីសំណាក់អ្នកវិនិយោគ ទៅឱ្យភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬភ្នាក់ងារដែលគេបានតែងតាំង និង

ខ) ភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬភ្នាក់ងារដែលគេបានតែងតាំងនោះមានសិទ្ធិ ដោយផ្អែកទៅលើឧបាទេសកម្ម ក្នុងការអនុវត្តនូវសិទ្ធិ និងការទាមទាររបស់អ្នកវិនិយោគនោះ ក្នុងពេលដែលគេទទួលខុសត្រូវលើវាល់កាតព្វកិច្ច ទាក់ទងទៅនឹងការវិនិយោគ ។

២) សិទ្ធិ ឬការទាមទារដែលផ្អែកទៅលើឧបាទេសកម្ម ពុំត្រូវមានកំរិតលើសពីសិទ្ធិ ឬការទាមទារពីដំបូងនៃអ្នកវិនិយោគនោះឡើយ ។

## មាត្រា ៨
## ការដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យាណាមួយ និង អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១) វិវាទណាមួយដែលកើតឡើងរវាងភាគីជាប់កិច្ចសន្យាណាមួយ និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងទៅនឹងការវិនិយោគ ប្រសិនបើអាចធ្វើទៅបាន ត្រូវដោះស្រាយដោយមិត្តភាពតាមរយៈការពិគ្រោះយោបល់រវាងភាគីមានវិវាទ

២) ប្រសិនបើការពិគ្រោះយោបល់ទាំងនោះមិនទទួលបាននូវលទ្ធផលនៅក្នុងអំឡុងពេល ០៦ ខែ គិតពីថ្ងៃមានសំណើសុំការដោះស្រាយ អ្នកវិនិយោគអាចលើកករណីវិវាទនោះតាមការជ្រើសរើសរបស់គេ ដើម្បីសុំការដោះស្រាយទៅ:

ក) តុលាការមានសមត្ថកិច្ច នៃភាគីជាប់កិច្ចសន្យានៅក្នុងទឹកដី ដែលការវិនិយោគបានធ្វើឬ

ខ) មជ្ឈត្តវិនិច្ឆ័យ ឬតុលាការមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្នដែលត្រូវបានបង្កើតឡើងដោយវិធានមជ្ឈត្តវិនិច្ឆ័យនៃគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ឬប្រធាននៃតុលាការមជ្ឈត្តវិនិច្ឆ័យត្រូវតែជាជនជាតិនៃប្រទេសទីបី ដែលមានទំនាក់ទំនងផ្លូវទូតជាមួយភាគីជាប់កិច្ចសន្យាទាំងពីរ ។

៣) ភាគីជាប់កិច្ចសន្យានីមួយៗ យល់ព្រមលើកសំណើនៃវិវាទវិនិយោគទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ឬធ្វើការចរចារ ។

៤) តុលាការមជ្ឈត្តវិនិច្ឆ័យត្រូវធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួនដោយឈរលើមូលដ្ឋាននៃច្បាប់ និងបទប្បញ្ញត្តិជាតិ នៃភាគីជាប់កិច្ចសន្យាដែលជាភាគីមានវិវាទ និងលើមូលដ្ឋាននៃបញ្ញត្តិរបស់កិច្ចព្រមព្រៀងនេះក៏ដូចជាវិធាននៃច្បាប់អន្តរជាតិ ដែលអាចអនុវត្តបាន ។ សេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យត្រូវតែជាសេចក្តីសម្រេចចុងក្រោយ និងត្រូវបានអនុវត្តដោយគូភាគីដែលមានវិវាទ ។

៥) មិនមានភាគីជាប់កិច្ចសន្យាណាមួយ អាចបន្តទាក់ទងតាមរយៈការទូតទេ នូវវិវាទដែលបានលើកស្នើឡើងទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិរួចហើយ លើកលែងតែភាគីជាប់កិច្ចសន្យាម្ខាងទៀតពុំបានគោរព និង ពុំបានអនុវត្តន៍ទៅតាមសេចក្តីសម្រេចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យ ។

### មាត្រា៩
### ការដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា

១) វិវាទណាមួយដែលអាចកើតឡើងរវាងភាគីជាប់កិច្ចសន្យាពាក់ព័ន្ធទៅនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយដោយមិត្តភាពតាមរយៈការពិគ្រោះយោបល់គ្នា ប្រសិនបើអាចធ្វើបាន ។

២) ប្រសិនបើភាគីទាំងពីរពុំបានឈានទៅដល់ការព្រមព្រៀងគ្នាក្នុងរយៈពេល ០៦ ខែ បន្ទាប់ពីការចាប់ផ្តើមនៃវិវាទជាមួយគ្នានោះ វិវាទត្រូវស្នើឡើងទៅតុលាការមជ្ឈត្តវិនិច្ឆ័យដែលមានសមាជិក ០៣រូប នៅពេលមានសំណើរបស់ភាគីជាប់កិច្ចសន្យាណាមួយ ។

៣) តុលាការមជ្ឈត្តវិនិច្ឆ័យនេះ ត្រូវបង្កើតឡើងសម្រាប់ករណីដោយឡែកនីមួយៗ តាមបែបបទ ដូចតទៅ:

ក) នៅក្នុងអំឡុងពេលបីខែបន្ទាប់ពីការទទួលសំណើដើម្បីឱ្យមានការធ្វើមជ្ឈត្តវិនិច្ឆ័យ ភាគីជាប់កិច្ចសន្យានីមួយៗត្រូវតែងតាំងរៀងៗខ្លួននូវមជ្ឈត្តករមួយរូប ។ មជ្ឈត្តករទាំងពីររូបនោះ ត្រូវជ្រើសរើសនូវជនជាតិនៃប្រទេសទីបីម្នាក់ ដែលជាប្រទេសមានទំនាក់ទំនងការទូតជាមួយភាគីជាប់កិច្ចសន្យាទាំងពីរ ហើយត្រូវបានទទួលការតែងតាំងជាប្រធាន នៃតុលាការ នៅពេលមានការយល់ព្រមរបស់ភាគីជាប់កិច្ចសន្យា ។ ប្រធានត្រូវតែទទួលបានការតែងតាំងនៅក្នុងអំឡុងពេលបីខែគិតចាប់ពីថ្ងៃដែលបានតែងតាំងមជ្ឈត្តករទាំងពីររូបទៀត ។

ខ) ប្រសិនបើនៅក្នុងអំឡុងរយៈពេលដែលបានបញ្ជាក់ក្នុង ចំណុច ក) កថាខ័ណ្ឌ ៣) នៃមាត្រានេះ ការតែងតាំងដ៏ចាំបាច់មិនត្រូវបានធ្វើទេ ភាគីជាប់កិច្ចសន្យាម្ខាងអាចអញ្ជើញប្រធានតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីធ្វើការតែងតាំងដ៏ចាំបាច់នោះ បើពុំមានកិច្ចព្រមព្រៀងផ្សេងណាមួយកំណត់ទេនោះ ។ ប្រសិនបើប្រធានគឺជាជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាង ឬប្រសិនបើគាត់ត្រូវបានហាមឃាត់មិនឱ្យបំពេញតួនាទីនោះ ដោយមូលហេតុណាមួយផ្សេងទៀត អនុប្រធានត្រូវបានទទួលការតែងតាំងដ៏ចាំបាច់នេះ ។ ប្រសិនបើអនុប្រធានគឺជាជនជាតិរបស់ភាគីជាប់កិច្ចសន្យាម្ខាង ឬក៏គាត់ត្រូវបានហាមឃាត់មិនឱ្យទទួលបន្ទុកការងារនោះ សមាជិកនៃតុលាការយុត្តិធម៌អន្តរជាតិថ្នាក់បន្ទាប់ ដែលមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ត្រូវបានទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៤) តុលាការមជ្ឈត្តវិនិច្ឆ័យត្រូវកំណត់នូវនីតិវិធីរបស់ខ្លួនដោយផ្ទាល់ ។ តុលាការមជ្ឈត្តវិនិច្ឆ័យត្រូវធ្វើការសម្រេចក្តីដោយឈរលើមូលដ្ឋាននៃបញ្ញត្តិរបស់កិច្ចព្រមព្រៀងនេះ និង កិច្ចព្រមព្រៀងដទៃទៀតដែលបានធ្វើឡើងរវាងភាគីជាប់កិច្ចសន្យាទាំងពីរ ។ តុលាការមជ្ឈត្តវិនិច្ឆ័យ ត្រូវសម្រេចក្តីរបស់ខ្លួនដោយ

ការបោះឆ្នោតយកសំឡេងភាគច្រើន ។ សេចក្តីសម្រេចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យ ជាសេចក្តីសម្រេចចុងក្រោយ និងត្រូវបានអនុវត្តន៍ដោយភាគីជាប់កិច្ចសន្យាទាំងពីរ ។

៥) ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវរ៉ាប់រងនូវសោហ៊ុយចំពោះមជ្ឈត្តករបស់ខ្លួននៅក្នុងដំណើរការមជ្ឈត្តវិនិច្ឆ័យ ។ ការចំណាយរបស់ប្រធានមជ្ឈត្តវិនិច្ឆ័យ និងចំណាយផ្សេងៗទៀតជាបន្ទុក ដែលភាគីជាប់កិច្ចសន្យាត្រូវចេញស្មើគ្នា ។

## ប្រការ ១០
## បញ្ញត្តិដែលមានភាពអនុគ្រោះច្រើនជាង និង ការតព្វកិច្ចផ្សេងៗ

១) ប្រសិនបើច្បាប់នឹងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាណាមួយ កិច្ចព្រមព្រៀងអន្តរជាតិដែលភាគីជាប់កិច្ចសន្យាទាំង ២ បានអនុវត្ត ឬកិច្ចព្រមព្រៀងធ្វើឡើងរវាងភាគីជាប់កិច្ចសន្យាមួយ និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតបន្ថែមទៅលើកិច្ចព្រមព្រៀងនេះ មានបញ្ញត្តិជាលក្ខណៈទូទៅ ឬពិសេសដែលអនុញ្ញាតឱ្យការវិនិយោគ នៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀតទទួលបាននូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះច្រើនជាងអ្វីដែលបានផ្តល់រួចហើយ ដោយកិច្ចព្រមព្រៀងនេះ បញ្ញត្តិទាំងនោះត្រូវយកមកអនុវត្តជំនួសកិច្ចព្រមព្រៀងនេះនៅត្រង់ចំណុចណាមានភាពអនុគ្រោះជាង ។

២) ភាគីជាប់កិច្ចសន្យានីមួយៗត្រូវពិនិត្យមើលការតព្វកិច្ចផ្សេងៗទៀត ដែលត្រូវទទួលបន្ទុកទាក់ទងទៅនឹងការវិនិយោគនៅក្នុងទឹកដីរបស់ខ្លួនដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

## មាត្រា ១១
## ការពិគ្រោះយោបល់ និង វិសោធនកម្ម

១) ភាគីជាប់កិច្ចសន្យានីមួយៗអាចលើកសំណើទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ដើម្បីធ្វើការពិគ្រោះយោបល់ទាក់ទងទៅនឹងសំនួរដែលពាក់ព័ន្ធទៅនឹងការអនុវត្តឬការបកស្រាយកិច្ចព្រមព្រៀងនេះ ។ ភាគីជាប់កិច្ចសន្យាទាំងពីរត្រូវប្រារព្ធធ្វើការពិគ្រោះយោបល់នៅទីកន្លែង និងពេលវេលាដែលបានយល់ព្រមជាមួយគ្នា ។

២) កិច្ចព្រមព្រៀងនេះអាចត្រូវបានធ្វើវិសោធនកម្មនៅគ្រប់ពេលវេលា ដោយមានការយល់ព្រមទៅវិញទៅមកជាលាយលក្ខណ៍អក្សររបស់ភាគីជាប់កិច្ចសន្យាទាំងពីរ "ប្រសិនបើចាំបាច់" ។

## មាត្រា ១២
## ទំហំវិសាលភាពនៃកិច្ចព្រមព្រៀង

បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តទៅលើការវិនិយោគទាំងអស់ ដែលបានធ្វើឡើងនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅពេលមុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀង ។ ទោះជាយ៉ាងនេះក៏ដោយ កិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះការខ្វែងគំនិត ឬវិវាទដែលបានកើតឡើងហើយ នៅមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រា ១៣
## ការចូលជាធរមាន ថេរវេលា និង ការបញ្ចប់

១) កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានគិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាទាំងពីរបានជូនដំណឹងគ្នាទៅវិញទៅមកថា តម្រូវការនៃរដ្ឋធម្មនុញ្ញសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវបានបំពេញរួចរាល់ហើយ ។

២) កិច្ចព្រមព្រៀងនេះស្ថិតនៅជាធរមានរយៈពេល ១០ ឆ្នាំ ។ កិច្ចព្រមព្រៀងនេះនឹងបន្តមានសុពលភាពជាស្វ័យប្រវត្តិសម្រាប់រយៈពេល ១០ ឆ្នាំ ទៀត លើកលែងតែភាគីជាប់កិច្ចសន្យាណាមួយបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតជាលាយលក្ខណ៍អក្សរយ៉ាងតិចណាស់ ១២ ខែ មុនថ្ងៃផុតសុពលភាពនៃកិច្ចព្រមព្រៀងអំពីបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀង ។

៣) ក្នុងករណីមានការជូនដំណឹងជាផ្លូវការ ដែលជាការបញ្ចប់នូវកិច្ចព្រមព្រៀងនេះ បញ្ញត្តិនៃមាត្រា ១ ដល់ ១២ ត្រូវបន្តមានប្រសិទ្ធភាពសម្រាប់រយៈពេល ១០ ឆ្នាំ បន្ថែមទៀត ចំពោះការវិនិយោគដែលបានធ្វើនៅមុនការជូនដំណឹងជាផ្លូវការ ។

ដើម្បីជាសក្ខីភាពនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលទទួលបាននូវសិទ្ធិប្រទានពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួនពីរច្បាប់ដើម នៅភ្នំពេញ នាថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៧ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាកូរ៉េ ដោយអត្ថបទទាំងបីមានតំលៃគតិយុត្តិស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយផ្សេងគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកធ្វើជាសំអាង ។

ជ.រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជ.រដ្ឋាភិបាលនៃសាធារណរដ្ឋ
ប្រជាមានិតប្រជាធិបតេយ្យកូរ៉េ

រីម ឃ្យុងម៉ាន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេស

# *Agreement*
# *between*
# *the Government of the Kingdom of Cambodia*
# *and*
# *the Government of the Democratic People's Republic of Korea*
# *for the Promotion and Protection of Investments*

*The Government of **the Kingdom of Cambodia** and the Government of the Democratic People's Republic of Korea, (hereinafter referred to as the "Contracting Parties"),*

*Desiring to intensify economic cooperation between both States on the basis of equality and mutual benefit,*

*Intending to create and maintain favorable conditions for investment by investors of one Contracting Party in the territory of the other Contracting Party,*

*Recognizing that the promotion and protection of such investments will be conducive to the stimulation of business initiative of investors of both Contracting Parties and the economic prosperity of both States,*

*Have agreed as follows:*

## *Article 1*
## *Definitions*

*For the purpose of this Agreement:*

*1) The term "investment" shall mean every kind of assets invested by investors of one Contracting Party in the territory of the other Contracting Party in accordance with the laws and regulations of the latter and in particular, though not exclusively, shall include:*
   *a) movable and immovable property and any other property rights such as mortgages and pledges;*
   *b) shares, stocks, debentures and any other forms of participation in companies;*
   *c) claims to money or to any other performance having an economic value;*
   *d) copyrights, industrial property rights such as patents, trademarks, service marks, trade names, industrial designs and indications of origin, know-how and any other similar rights,*
   *e) business concessions conferred by laws, under contracts or by decision of the authority in accordance with the law, including concessions to search for, cultivate, extract or exploit natural resources.*

*Any alterations of the form in which assets are invested or are reinvested shall not affect their character as an investment, provided that such investment or reinvestment does not contradict to the laws and regulations of the Contracting Party in whose territory the investment were made.*

2) *The term "investor" refers with regard to either Contracting Party to:*
   a) *natural persons who, according to the law of that Contracting Party, are considered to be its nationals*
   b) *legal entities, including companies, business associations and other organizations, which are constituted or otherwise duly organized under the law of that Contracting Party and have their seat, together with real economic activities, in the territory of the same Contracting Party*

3) *The term "returns" means amounts yielded by an investment such as profits, interests, dividends, capital gains, royalties and fee.*
4) *The term "territory" shall mean:*
   a) *in respect of the Kingdom of Cambodia, the territorial land, territorial sea, its sea-bed and subsoil and airspace over which the Kingdom of Cambodia exercises sovereign rights or jurisdiction in accordance with its national law and international law;*
   b) *in respect of the Democratic People's Republic of Korea, the territorial land, territorial sea, exclusive economic maritime zone and continental shelf over which it exercises sovereign rights or jurisdiction in accordance with its national law and international law;*

## *Article 2*
## *Promotion and Protection of Investments*

1) *Each Contracting Party shall in its territory promote investments by investors of the other Contracting Party, create favourable conditions for their investments and admit such investments in accordance with its laws and regulations. When one Contracting Party shall have admitted an investment on its territory, it shall give facilities for the entry sojourn of nationals of the other Contracting Party or their employed persons who wish to enter its territory in connection with such an investment.*

2) *Investments of investors of either Contracting Party shall at all times be accorded fair and equitable treatment and shall enjoy full protection and security in the territory of the other Contracting Party. Neither Contracting Party shall in any way impair by unreasonable or discriminatory measures the management, maintenance, use, enjoyment or disposal of such investments.*

## *Article 3*
## *Treatment of Investments*

*1) Each Contracting Party shall in its territory accord to investments and returns of investors of the other Contracting Party treatment not less favourable than that which it accords to investments and returns of its own investors or investors of any third State, whichever is more favourable.*

*2) Each Contracting Party shall in its territory accord investors of the other Contracting Party, as regards the management, maintenance, use, enjoyment or disposal of their investment, treatment not less favourable than that which it accords to its own investors or investors of any third State, whichever is more favourable.*

*3) The provisions of most-favoured-nation treatment of this Article shall not be construed so as to oblige one Contracting Party to extend to the investors of the other Contracting Party the benefit of any treatment, preference or privilege, which may be extended by the former Contracting Party by virtue of:*

*a) any custom union, free trade area, monetary union or similar international agreements leading to such unions or other forms of regional cooperation to which either Contracting Party is or may become a party;*

*b) any international agreements or arrangements relating wholly or mainly to taxation.*

## ***Article 4***
## ***Expropriation***

*1) Investments of investors of either Contracting Party shall not be expropriated, nationalized or subject to measure having the same effect (hereinafter referred to as "expropriation") in the territory of the other Contracting Party except for the public interest, under due process of law, on a non-discriminatory basis and against prompt, adequate and effective compensation.*

*2) The compensation shall amount to the market value of the expropriated investments immediately before the expropriation take place or before the impending expropriation becomes public knowledge, whichever is earlier. Such compensation shall include the interest that has accrued at a commercially reasonable rate from the date when the payment is due until the date of actual payment and shall be paid in a freely convertible currency without delay to the person entitled thereto.*

### *Article 5*
### *Compensation of Losses*

*Investors of one Contracting Party whose investments suffer losses owing to war or other armed conflict, revolution, state of emergency, revolt, insurrection, riot or other similar events in the territory of the other Contracting Party shall be accorded by the latter Contracting Party treatment in accordance with Article 3 of this Agreement as regards restitution, indemnification, compensation or other settlement.*

### *Article 6*
### *Free Transfer*

1) *Each Contracting Party in whose territory investments shall have been made by investors of the other Contracting Party shall grant those investors the free transfer, in a freely convertible currency, of the funds relating to these investments, in particular of:*
   a) *capital and additional capital amounts necessary for the maintenance and development of the investment;*
   b) *returns;*
   c) *repayments of loans relating to investments;*
   d) *the proceeds from the total or partial sale or liquidation of the investment;*
   e) *compensation and other payments due to be paid in accordance with Article 4 and 5;*
   f) *the salaries and other legitimate earnings of the persons engaged from abroad in connection with the investment.*
   g) *payments arising out of the settlement of a dispute.*

2) *Transfers shall be made without delay at the market rate of exchange prevailing on the date of the transfer in the territory of that Contracting Party.*

3) *Each Contracting Party shall accord investors of the other Contracting Party treatment not less favourable than that accorded to investors of any third State in connection with the transfers.*

### *Article 7*
### *Subrogation*

1) *If either Contracting Party or its designated agency makes payment to one of its investors under any financial guarantee against non-commercial risks it has accorded in respect of an investment by its investor in the territory of the other Contracting Party, the latter Contracting Party shall recognize:*

*a) the assignment, whether under the law or pursuant to a legal transaction, of any right or claim from the investor to the former Contracting Party or its designated agency; and*

*b) that the former Contracting Party or its designated agency is entitled by virtue of subrogation to exercise the right and to enforce the claim of that investor while it will assume the obligations relating to the investment.*

*2) The right or claim by virtue of subrogation shall not exceed the original right or claim of the investor.*

## *Article 8*
## *Settlement of Disputes between a Contracting Party and an Investor of the other Contracting Party*

*1) Any dispute which may arise between a Contracting Party and an investor of the other Contracting Party in connection with an investment shall, as far as possible, be settled amicably through consultations between the parties to the dispute.*

*2) If these consultations do not result in a solution within six months from the date of request for settlement, the investor may submit the dispute, at his choice, for settlement to:*

*a) the competent court of the Contracting Party in the territory of which the investment has been made; or*

*b) an arbitrator or* ***ad hoc*** *arbitral tribunal which shall be established under the arbitration rules of the United Nations Commission on International Trade Law (UNCITRAL); or*

*The Chairperson of such an arbitral tribunal shall be a national of a third country which has diplomatic relations with the Contracting Parties.*

*3) Each Contracting Party hereby consents to the submission of an investment dispute to international arbitration or conciliation.*

*4) The arbitral tribunal shall make its decision on the basis of national laws and regulations of the Contracting Party, which is a party to the dispute, and the provisions of the present Agreement, as well as applicable rules of international law. The arbitral awards shall be final and binding on the parties to the dispute.*

*5) Neither Contracting Party shall pursue, through diplomatic channel, a dispute submitted to international arbitration unless the other Contracting Party does not abide by and comply with the award rendered by an arbitral tribunal.*

### *Article 9*
### *Settlement of Disputes between the Contracting Parties*

*1) Any dispute which may arise between the Contracting Parties concerning the interpretation or application of this Agreement shall, as far as possible, be settled amicably through consultations.*

*2) If both Contracting Parties do not reach an agreement within six months after the beginning of the dispute between themselves, the dispute shall, upon request of either Contracting Party, be submitted to an arbitral tribunal of three members.*

*3) Such an arbitral tribunal shall be constituted for each individual case in the following way:*

*a) Within three months of receipt of the request for arbitration, each Contracting Party shall appoint one arbitrator respectively. These two arbitrators shall then select a national of a third country, which has diplomatic relations with both Contracting Parties, who upon approval by the Contracting Parties shall be appointed Chairperson of the tribunal. The Chairperson shall be appointed within three months from the date of appointment of the other two arbitrators.*

*b) If within the periods specified in a), paragraph 3) of this Article the necessary appointments have not been made, either Contracting Party may, in the absence of any other agreement, invite the President of the International Court of Justice to make the necessary appointments. If the President is a national of either Contracting Party or is otherwise prevented from discharging the said function, the Vice-President shall be invited to make the necessary appointments. If the Vice-President is a national of either Contracting Party or is also prevented from discharging the said function, the Member of the International Court of Justice next in seniority, who is not a national of either Contracting Party shall be invited to make the necessary appointments.*

*4) The arbitral tribunal shall determine its own procedure. The arbitral tribunal shall make its decision on the basis of the provisions of the present Agreement and other agreements concluded between the Contracting Parties. The arbitral tribunal shall reach its decision by a majority of votes.*
*The decisions of the tribunal shall be final and binding upon both Contracting Parties.*

*5) Each Contracting Party shall bear the costs of its own arbitrator in the arbitral proceedings. The costs of the Chairperson and the remaining costs shall be borne in equal parts by the Contracting Parties.*

*Article 10*
***More Favourable Provisions and Other Obligations***

1) *If the laws and regulations of either Contracting Party, international agreements which are binding upon both Contracting Parties or the agreements concluded between one Contracting Party and investors of the other Contracting Party in addition to this Agreement contain provisions, whether general or specific, entitling investments of investors of the other Contracting Party to treatment more favourable than that provided for by the present Agreement, such provisions shall, to the extent that they are more favourable, prevail over this Agreement.*

2) *Each Contracting Party shall observe any other obligations it may have assumed with regard to investments in its territory by investors of the other Contracting Party.*

*Article 11*
***Consultation and Amendment***

1) *Each Contracting Party may propose to the other Contracting Party to enter into consultation concerning all questions related to the implementation or interpretation of the present Agreement. Both Contracting Parties shall hold consultations in the place and times agreed with each other.*

2) *This Agreement may be amended at any time, if deemed necessary, by mutual consent of both Contracting Parties in writing.*

*Article 12*
***Application of Agreement***

*The provisions of this Agreement shall apply to all investments made in the territory of one Contracting Party prior to or after the entry into force of the Agreement by investors of the other Contracting Party. It shall, however, not be applicable to divergences or dispute which have arisen prior to its entry into force.*

*Article 13*
***Entry into Force, Duration and Termination***

1) *This Agreement shall enter into force from the date when both Contracting Parties notify each other that their constitutional requirements for the entry into force of this Agreement have been fulfilled.*

2) *This Agreement shall remain in force for a period of ten years. It shall automatically continue to be valid for further period of ten years unless either Contracting Party notifies the other Contracting Party in writing at least twelve months prior to the expiry date of this Agreement of its intention to terminate the Agreement.*

3) *In case of official notice as to the termination of the present Agreement, the provisions of Articles 1 to 12 shall continue to be effective for a further period of ten years for the investments made before official notice was given.*

***IN WITNESS WHEREOF**, the undersigned, duly authorized thereto by their respective Governments, have signed this Agreement.*

*Done in **duplicate**, at Phnom Penh, on 1st November 2007, in Khmer, Korean and English languages, all texts being equally authentic. In case of any divergence of interpretation of this Agreement, the English text shall prevail.*

***For the Government of the Kingdom of Cambodia***

***Cham Prasidh***
***Senior Minister,***
***Minister of Commerce***

***For the Government of the Democratic People's Republic of Korea***

***Rim Kyong Man***
***Minister of Foreign Trade***

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលបានប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម **ខួន ញឹម** ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានតែងតាំងជូន :

១-ឯកឧត្តម **ជា ជាតិ** ជាទីប្រឹក្សាឯកឧត្តម **ខួន ញឹម** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២-ឯកឧត្តម **គីម សាន់** ជាទីប្រឹក្សាឯកឧត្តម **ខួន ញឹម** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា២.-** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣.-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៧៤៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៩

៣.ល. ០៩០៧.៧១៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

**អគ្គលេខាធិការស្តីទីរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ ដូចមានរាយនាមខាងក្រោម :

១-លោក **សុខ សុភេន** អនុមន្ត្រីថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
២-លោក **ឡុង គៃមចិត្រ** អនុមន្ត្រីថ្នាក់លេខ ១៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

៣៩៧.០៩០៩.៩២៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

លេខៈ ៧៦០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសព នាយទាហាន ក្រសួងការពារជាតិ និង មេបញ្ជាការរង កងពលតូចលេខ៣១ ចំនួន ០២ រូប :

**ក_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

-ឧត្តមសេនីយ៍ត្រី **ទ៊ែន ផាត** អត្តលេខ ០០៣៤៧៩

**ខ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមនាវីទោ**

-ឧត្តមនាវីត្រី **ខៀវ រិទ្ធ** អត្តលេខ ០១៥៧០៣

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ.ល.០៩០៩.៧២០

លេខ:៧៥៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ សីហា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៨០៩/៧២០

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

ROYAUME DU CAMBODGE

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់**ក្រសួងពាណិជ្ជកម្ម** ចំនួន **៣២** រូប និង**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** ចំនួន ០១ រូប គិតចាប់ពីថ្ងៃទី **០១** ខែ **កញ្ញា** ឆ្នាំ **២០០៨** ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ |
|---|---|---|---|
| **ក្រសួងពាណិជ្ជកម្ម** | | | |
| ១ | **លី សុណាមិន** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ២ | **ហេង សំបូរ** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៣ | **សុខ ហុង** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៤ | **តា ប៊ុនរិទ្ធ** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៥ | **ហ៊ី ដារ៉ា** | ស | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៦ | **លី ឡាមី** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៧ | **ម៉ែល ម៉ារិន** | ស | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៨ | **អ៊ុំ សារ៉េត** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ៩ | **ឆាយ ធុត្ថា** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១០ | **សុខ វណ្ណធុល** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១១ | **ជួប សុមេធ** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១២ | **ស៊ិន សារ៉ាយ** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៣ | **កែវ ពិសី** | ស | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៤ | **នឹម មាឃផលឡែន** | ស | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៥ | **ថុន ចាន់ធី** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៦ | **ទិត បញ្ញា** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៧ | **ចន្សៀ ចំនួសុវណ្ណារិទ្ធ** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៨ | **ខែម បូរ៉ាមី** | ស | អនុមន្ត្រី ថ្នាក់លេខ **១៤** |
| ១៩ | **[illegible] នីរត្នឧត្តមបញ្ញា** | ប | អនុមន្ត្រី ថ្នាក់លេខ **១៤** |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ២០ | អ៊ុម អក្ខរផល | ស | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២១ | អឿង សុផាន់ណា | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២២ | ម៉ៅ គីមសាយ | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៣ | ណាល់ ចណ្ណះ | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៤ | ហៃ វិចិត្រ | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៥ | យន្ត ដានី | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៦ | អេង ប៊ូលុច | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៧ | លី វិចិត្រ | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៨ | គ្រឹម ម៉ារ៉ាឌី | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ២៩ | គឿន គីមលី | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣០ | អាន សុភា | ស | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣១ | អឿង ស៊ីរ៉ែន | ប | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ៣២ | ឈឿង ឡាពី | ស | អនុមន្ត្រី ថ្នាក់លេខ ១៤ |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | | | |
| ៣៣ | សុខ ចាសនា | ប | អនុមន្ត្រី ថ្នាក់លេខ ១១ |

**មាត្រា ២ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** ចំនួន **៤២** រូប គិតចាប់ពីថ្ងៃទី **១៥** ខែ **សីហា** ឆ្នាំ **២០០៨** ដូចមានរាយនាមខាងក្រោម :

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និង ថ្នាក់ |
|---|---|---|---|
| ១ | ទេព ណារិន | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២ | អូន ចណ្ណារ៉ា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៣ | ឌ សុផាន់ណា | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៤ | អឿង ចណ្ណារិទ្ធ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៥ | ខឹម បូរិន | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៦ | ហង់ រិទ្ធី | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៧ | សុខ ពុធចណ្ណារាយ | ប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៨ | ផេង ថាវី | ស | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
